**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំយុវជន និង កីឡា**

**លេខ : ៤០៩ អយក.ប្រក**

**ប្រកាស**

ស្តីពីការបើកសាលាបឋមសិក្សា **តាគីម**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិត ១១៤៤ អយក.គបម ចុះថ្ងៃទី ២៨ ខែ ១ ឆ្នាំ ២០០១ របស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត តាកែវ
- តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**<u>សំរេច</u>**

**ប្រការ១** :-បើកសាលាបឋមសិក្សា **តាគីម** ដែលមានទីតាំងស្ថិតនៅ ឃុំ **ត្រពាំងក្រសាំង** ស្រុក **បាទី** ខេត្ត **តាកែវ** ជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :-សាលាបឋមសិក្សា **តាគីម** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** :-បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** :-នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **តាកែវ** ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក **បាទី** នាយកសាលាបឋមសិក្សា **តាគីម** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ .ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០២

**ជ-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

រដ្ឋលេខាធិការ

**អ៊ឹម_សិទ្ធិ**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " <u>ដើម្បីជូនជ្រាបជាពតិមាន</u> "
- សាលាខេត្ត តាកែវ " <u>ជូនជ្រាបជាពតិមាន</u> "
- ដូចប្រការ ៤
- កាលប្បវត្តិ
- ឯកសារ នា.បម